**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យ លេខ ១៦អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យ លេខ ២៦អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១ -**

ត្រូវផ្ទេរពីថវិកាជាតិទៅគណនីមូលនិធិឃុំ សង្កាត់ សម្រាប់ថេរៈវេលាបីឆ្នាំ ដោយកំណត់ជាភាគរយនៃចំណូលចរន្តរបស់ថវិកាជាតិ ដូចខាងក្រោម ៖

- ឆ្នាំថវិកា២០១១ : មិនត្រូវតិចជាង២,៨០% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១០
- ឆ្នាំថវិកា២០១២ : មិនត្រូវតិចជាង២,៨០% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១១
- ឆ្នាំថវិកា២០១៣ : មិនត្រូវតិចជាង២,៨០% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១២

**មាត្រា ២-**

ធនធានមូលនិធិសរុបដែលបានមកពីការចូលរួមរបស់ថវិកាជាតិ ដូចដែលមានកំណត់ក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ការចូលរួមពីជំនួយឥតសំណង និងការខ្ចីដែលបានមកពីដៃគូអភិវឌ្ឍន៍នានា ត្រូវបែងចែកជាពីរសមាសភាគ ហើយត្រូវបានកំណត់សមាមាត្រសម្រាប់រយៈពេលពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ចំពោះសមាសភាគនីមួយៗ ដូចខាងក្រោម ៖

| ឆ្នាំថវិកា | សមាសភាគរដ្ឋបាលទូទៅ | សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន |
|---|---|---|
| ឆ្នាំថវិកា២០១១ | មិនត្រូវច្រើនជាងមួយភាគបី | មិនត្រូវតិចជាងពីរភាគបី |
| ឆ្នាំថវិកា២០១២ | មិនត្រូវច្រើនជាងមួយភាគបី | មិនត្រូវតិចជាងពីរភាគបី |
| ឆ្នាំថវិកា២០១៣ | មិនត្រូវច្រើនជាងមួយភាគបី | មិនត្រូវតិចជាងពីរភាគបី |

**មាត្រា ៣-**

ធនធាននៃសមាសភាគរដ្ឋបាលទូទៅ ត្រូវបានប្រើប្រាស់សម្រាប់ចំណាយទាំងឡាយដូចបានចែងក្នុងកថាខ័ណ្ឌទី២ មាត្រា១៥ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងសម្រាប់ចំណាយឧបត្ថម្ភដល់មន្ត្រីភូមិតាមរបបកំណត់ជាធរមាន ។

ធនធាននៃសមាសភាគរដ្ឋបាលទូទៅរួមមាន ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល ចំណាយសម្រាប់ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ និង មន្ត្រីភូមិ ។

ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល ត្រូវបានគណនាដោយយកធនធាននៃសមាសភាគរដ្ឋបាលទូទៅដកចេញនូវចំណាយសម្រាប់ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ រួចទើបធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៤-**

ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានប្រើប្រាស់សម្រាប់ចំណាយទាំងឡាយដូចដែលមានចែង ក្នុងកថាខណ្ឌទី៣ នៃមាត្រា១៥ នៃអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងត្រូវបានវិភាជន៍ទៅឲ្យឃុំ សង្កាត់នីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

- ចំណែកស្មើគ្នាជាមូលដ្ឋាន
- ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ (ដោយផ្អែកតាមឯកសាររបស់ក្រសួងផែនការ )
- សន្ទស្សន៍ភាពក្រីក្រនៃ ឃុំ សង្កាត់នីមួយៗ (ដោយផ្អែកតាមឯកសាររបស់ក្រសួងផែនការ )

សមាមាត្រនៃមូលនិធិអភិវឌ្ឍន៍មូលដ្ឋានចំពោះសន្ទស្សន៍នីមួយៗខាងលើ ត្រូវបានកំណត់ដូចខាងក្រោម៖

| ឆ្នាំថវិកា | ចំណែកស្មើគ្នាជាមូលដ្ឋាន | ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ | សន្ទស្សន៍ភាពក្រីក្រ ក្នុងឃុំសង្កាត់នីមួយៗ |
|---|---|---|---|
| ឆ្នាំថវិកា២០១១ | ៣៥% | ៣៥% | ៣០% |
| ឆ្នាំថវិកា២០១២ | ៣៥% | ៣៥% | ៣០% |
| ឆ្នាំថវិកា២០១៣ | ៣៥% | ៣៥% | ៣០% |

**មាត្រា ៥-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគណនា និងជូនដំណឹងជាផ្លូវការអំពីចំនួនធនធានវិភាជន៍ដែលឃុំ សង្កាត់នីមួយៗត្រូវទទួលបានសម្រាប់ឆ្នាំបន្ទាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែតុលា នៃឆ្នាំថវិកាកំពុងអនុវត្ត។ គម្រោងថវិកាត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យនិងអនុម័ត ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តគម្រោងថវិកា នាកិច្ចប្រជុំជាសាធារណៈ ឲ្យបានមុនថ្ងៃទី ៣១ ខែ តុលា បន្ទាប់មកមេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនគម្រោងថវិកាដែលបានអនុម័តរួចទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឲ្យបានមុនថ្ងៃទី ០៥ ខែ វិច្ឆិកា ដើម្បីសុំការបញ្ជាក់ទទួលស្គាល់ពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមិនឲ្យហួសថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំជាក់ហិត។

**មាត្រា ៦-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់ចែងធ្វើការផ្ទៀងផ្ទាត់ដោយធ្វើអធិការកិច្ចហិរញ្ញវត្ថុឬការត្រួតពិនិត្យហិរញ្ញវត្ថុតាមការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិច្បាប់ដែលមានការពាក់ព័ន្ធជាធរមាន។

**មាត្រា ៧-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៨-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ទាំងអស់ត្រូវអនុវត្តតាមអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ស ខេង** **គាត ឈន់**

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ដូចចែងក្នុងមាត្រា៨
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ